ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១០៧. អនក្រ .បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតគណៈកម្មាធិការជាតិបរិស្ថាននិងសុខភាព

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខនស/រកម /០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៥៧អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៦៧អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសុខាភិបាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០១០

# សម្រេច

## ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិបរិស្ថាននិងសុខភាព ដែលសរសេរអក្សរកាត់ថា **គ.ជ.ប.ស.** ។

គ.ជ.ប.ស. ជាយន្តការសម្របសម្រួលថ្នាក់ជាតិ និងពិគ្រោះយោបល់លើបញ្ហាបរិស្ថានដែលប៉ះពាល់ដល់សុខភាពសាធារណៈ ។

## ជំពូកទី២

### សមាសភាពរបស់ គ.ជ.ប.ស.

**មាត្រា២.-**

គ.ជ.ប.ស. មានសមាសភាពដូចតទៅ៖

| | | | |
|---|---|---|---|
| -រដ្ឋមន្ត្រី | ក្រសួងសុខាភិបាល | | ប្រធាន |
| -រដ្ឋលេខាធិការ | ក្រសួងបរិស្ថាន | ១រូប | អនុប្រធាន |
| -រដ្ឋលេខាធិការ | ក្រសួងអភិវឌ្ឍន៍ជនបទ | ១រូប | អនុប្រធាន |
| -រដ្ឋលេខាធិការ | ក្រសួងសុខាភិបាល | ១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| -រដ្ឋលេខាធិការ | ទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | សមាជិក |
| -រដ្ឋលេខាធិការ | ក្រសួងមហាផ្ទៃ | ១រូប | សមាជិក |
| -រដ្ឋលេខាធិការ | ក្រសួងការពារជាតិ | ១រូប | សមាជិក |
| -រដ្ឋលេខាធិការ | ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ១រូប | សមាជិក |
| -រដ្ឋលេខាធិការ | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ១រូប | សមាជិក |
| -រដ្ឋលេខាធិការ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១រូប | សមាជិក |
| -រដ្ឋលេខាធិការ | ក្រសួងផែនការ | ១រូប | សមាជិក |
| -រដ្ឋលេខាធិការ | ក្រសួងពាណិជ្ជកម្ម | ១រូប | សមាជិក |
| -រដ្ឋលេខាធិការ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១រូប | សមាជិក |
| -រដ្ឋលេខាធិការ | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ១រូប | សមាជិក |

-រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងធនធានទឹក និង ឧតុនិយម ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងព័ត៌មាន ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងសាធារណការ និង ដឹកជញ្ជូន ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ១រូប សមាជិក

-រដ្ឋលេខាធិការ ក្រសួងធម្មការ និង កិច្ចការសាសនា ១រូប សមាជិក

-អគ្គលេខាធិការ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ សមាជិក។

សមាសភាពជាក់ស្តែងរបស់ **គ.ជ.ប.ស.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣

## ភារកិច្ចរបស់ គ.ជ.ប.ស.

**មាត្រា៣.-**

**គ.ជ.ប.ស.** មានភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិនៃបរិស្ថាន និងសុខភាព ដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- ជំរុញ និងតាមដានការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិនៃបរិស្ថាន និងសុខភាព ដើម្បីលើកកម្ពស់ការការពារបរិស្ថាននិងសុខភាពរបស់ប្រជាពលរដ្ឋ ដែលជាកត្តាចម្បងសម្រាប់ ការអភិវឌ្ឍធនធានមនុស្ស វឌ្ឍនភាពសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកប ដោយចីរភាព

- បង្កើនកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយបណ្តាស្ថាប័ននៅគ្រប់ថ្នាក់ គ្រប់ផ្នែក ជាពិសេសប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាសហគមន៍អន្តរជាតិលើវិស័យបរិស្ថាននិងសុខភាព
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារ ស្តីពីបរិស្ថាននិងសុខភាពជូនរាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន ។

## ជំពូកទី៤

## ការប្រព្រឹត្តទៅរបស់ គ.ជ.ប.ស.

**មាត្រា៤.-**

សមាជិក **គ.ជ.ប.ស.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**គ.ជ.ប.ស.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសុខាភិបាល ។

**មាត្រា៥.-**

**គ.ជ.ប.ស.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ដោយឡែក នៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងសុខាភិបាល ។

**គ.ជ.ប.ស.** អាចទទួលធនធានផ្គត់ផ្គង់ដោយមូលនិធិជាហិរញ្ញប្បទាន ដែលបានមកពីដៃគូអភិវឌ្ឍ និងពីប្រភពផ្សេងៗសម្រាប់បំពេញការងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាពខ្ពស់ ។

**គ.ជ.ប.ស.** មានក្រុមការងារបច្ចេកទេសមួយចំនួនតាមការចាំបាច់ ។ សមាសភាពនិងតួនាទី ភារកិច្ចរបស់ក្រុមការងារបច្ចេកទេស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.ជ.ប.ស.** ។

**គ.ជ.ប.ស.** មាននាយកដ្ឋានការពារសុខភាពនៃក្រសួងសុខាភិបាលជាលេខាធិការដ្ឋាន ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងមាត្រា២ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ៦/៧ ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៧

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ